ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

Ministry of Foreign Affairs and International Cooperation

# បច្ចុប្បន្នភាពស្ដីពី ស្ថានការណ៍ព្រំដែនកម្ពុជា-ថៃ

# UPDATES ON CAMBODIA-THAILAND BORDER SITUATION

Ministry of Foreign Affairs and
International Cooperation
Kingdom of Cambodia
OFFICE OF THE SPOKESPERSON

# បច្ចុប្បន្នភាពស្តីពីស្ថានការណ៍ព្រំដែនកម្ពុជា-ថៃ
# ថ្ងៃទី១៣-១៥ ខែតុលា ឆ្នាំ២០២៥

I. នៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២៥ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យ ឯកឧត្តម Dato Seri' Ahmad Zahid bin Hamidi ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍តំបន់ និងជនបទ នៃសហព័ន្ធម៉ាឡេស៊ី ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ —

ពាក់ព័ន្ធនឹងបញ្ហាព្រំដែនរវាងកម្ពុជានិងថៃ **សម្តេចតេជោ** បានពន្យល់ទៅកាន់ **ឯកឧត្តម ឧបនាយក-រដ្ឋមន្ត្រីម៉ាឡេស៊ី** អំពីស្ថានភាពនៃបញ្ហាព្រំដែន រួមទាំងស្ថានភាពទាក់ទងទៅនឹងការចាក់សម្លេងខ្មោច ឬក៏សម្លេង ផ្សេងៗទៀតដោយភាគីថៃ ដែលធ្វើអោយប៉ះពាល់រំខានដល់ពលរដ្ឋកម្ពុជារស់នៅក្នុង**ភូមិជោគជ័យ** និង**ភូមិព្រៃចាន់**ជាដើម អស់រយៈពេលប្រមាណ **៤យប់**មកហើយ។

សម្តេចតេជោ បានបញ្ជាក់ថា អ្វីដែលកម្ពុជាចង់បានគឺ មិនត្រូវការឱ្យប្រទេសណាមួយ សម្ព័ន្ធមិត្ត ឬក៏មិត្តរបស់កម្ពុជាទៅថ្កោលទោសប្រទេសណាទេ។ ប៉ុន្តែ អ្វីដែលកម្ពុជាចង់បានគឺ ការធ្វើយ៉ាងណាជំរុញឱ្យភាគីទាំងពីរគោរពបទឈប់បាញ់ឱ្យមានប្រសិទ្ធភាព និងការស្វែងរកដំណោះស្រាយដើម្បីឈានទៅរកប្រក្រតីភាពនៃទំនាក់ទំនងរវាងកម្ពុជា និងថៃឡើងវិញ។

**សម្តេចតេជោ** ក៏បានបង្ហាញនូវការគោរព ចំពោះតួនាទីស្នូលរបស់ឯកឧត្តមនាយករដ្ឋមន្ត្រីម៉ាឡេស៊ី ដែលមានសារៈសំខាន់ក្នុងការធ្វើយ៉ាងណា ទាំងការធានាបទឈប់បាញ់ និងការដោះស្រាយបញ្ហារវាងកម្ពុជា និងថៃ ក្នុងឋានៈឯកឧត្តមជាប្រធានអាស៊ាន។

II. អ្នកនាំពាក្យព្រឹទ្ធសភាកម្ពុជា — ក្នុងការឆ្លើយតបចំពោះសេចក្តីថ្លែងការណ៍របស់អ្នកនាំពាក្យក្រសួងការពារជាតិថៃ ដែលបានថ្លែងនៅថ្ងៃទី ១៥ ខែតុលា ឆ្នាំ ២០២៥ អះអាងថា "សម្តេចតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភាកម្ពុជា បានដាក់សម្ពាធឲ្យប្រទេសថៃបើកច្រកព្រំដែនកម្ពុជា-ថៃវិញត្រឹមដល់ខែតុលា ឆ្នាំ ២០២៥" — ដោយបានឆ្លើយបញ្ជាក់ថា សម្តេចតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភាកម្ពុជា បានបញ្ជាក់ជាបន្តបន្ទាប់អំពីជំហររបស់សម្តេចរួចហើយ។ កាលពីថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ២០២៥ តាមរយៈទំព័រហ្វេសប៊ុកផ្លូវការរបស់សម្តេច សម្តេចតេជោ ហ៊ុន សែន បានបញ្ជាក់ថា «ដោយតាំងពីយោធាថៃជាអ្នកបិទព្រំដែនជាឯកតោភាគីមក កម្ពុជាមិនដែលស្នើសុំឱ្យថៃបើកច្រកវិញឡើយ។ កម្ពុជាគ្រាន់តែជម្រាបជូនភាគីថៃថា ព្រោះថៃជាអ្នកបិទ ដូច្នេះថៃក៏គួរតែជាអ្នកបើកវិញផងដែរ ដោយមិនចាំបាច់ចរចាជាមួយកម្ពុជាទេ ហើយកម្ពុជានឹងបើកច្រកខ្លួនឯងបន្ទាប់ពី៥ម៉ោងក្រោយមក។»

III. **នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២៥ សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី បានអញ្ជើញចូលរួម កិច្ចប្រជុំថ្នាក់ដឹកនាំពិភពលោកស្តីពីស្ត្រី នៅសាធារណរដ្ឋប្រជាមានិតចិន** — ថ្លែងក្នុងសុន្ទរកថាបើក **សម្តេចរដ្ឋសភាធិបតី** បាន «អំពាវនាវដល់សហគមន៍អន្តរជាតិ តាមដានឱ្យបានជិតដល់លើការអនុវត្តបទឈប់បាញ់ដែលមានលក្ខណៈផុយស្រួយរវាងកម្ពុជា-ថៃ ដើម្បីស្តារនូវសន្តិភាព និងប្រក្រតីភាពឡើងវិញ» ដោយបញ្ជាក់ថា «សន្តិភាពជាបុរេលក្ខខណ្ឌដ៏ចាំបាច់ ដើម្បីសម្រេចបាននូវគោលបំណងរួមរបស់យើង។»

សម្តេចរដ្ឋសភាធិបតី ក៏បានលើកឡើងជាថ្មីថា កម្ពុជាបានប្រកាន់ជំហរសន្តិភាព អត់ធ្មត់ដោយសារមិនចង់ឃើញប្រជាពលរដ្ឋនៃប្រទេសទាំងពីររងគ្រោះកាន់តែធ្ងន់ធ្ងរពីសង្គ្រាមឡើយ។ គូសរំលេចថា *កម្ពុជាបានព្យាយាមតាមដោះស្រាយបញ្ហាដោយសន្តិវិធី តាមយន្តការទ្វេភាគី គោរពធម្មនុញ្ញអាស៊ាន ធម្មនុញ្ញអង្គការសហប្រជាជាតិ និងច្បាប់អន្តរជាតិនានា ដើម្បីធ្វើយ៉ាងណាឱ្យស្ថានការណ៍ព្រំដែនវិលទៅសភាពប្រក្រតីភាព ឡើងវិញ។*

IV. នៅព្រឹកថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២៥ ក្រសួងការពារជាតិ នៃព្រះរាជាណាចក្រកម្ពុជា បានសម្របសម្រួលជូនក្រុមអ្នកសង្កេតការណ៍អន្តរកាល (IOT) ដឹកនាំដោយប្រទេសម៉ាឡេស៊ី រួមនិងសមាជិក បានអញ្ជើញចុះពិនិត្យទីតាំងជាក់ស្តែង ដែលរងផលប៉ះពាល់ តាមរយៈការប្រើប្រាស់យន្តហោះចម្បាំងទំលាក់គ្រាប់ MK-84 នៅភូមិសែនរុងរឿង៤ ឃុំមរកត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ដើម្បីសង្កេតការណ៍ ផ្ទៀងផ្ទាត់ និងរាយការណ៍ ក្រោយបទឈប់បាញ់បានចូលជាធរមាន ឱ្យបានច្បាស់លាស់ ត្រឹមត្រូវ និងមិនលម្អៀង ស្របតាមអាណត្តិរបស់ខ្លួននៅក្នុងការធានាការអនុវត្តបទឈប់បាញ់ឱ្យបានពេញលេញ និងមានប្រសិទ្ធភាព។

V. គិតត្រឹមថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២៥ ជា**ថ្ងៃទី ៧៨ ហើយ** ដែល**វីរកងទ័ពកម្ពុជាចំនួន ១៨រូប** ត្រូវបានចាប់ឃុំខ្លួនដោយយោធាថៃដោយខុសច្បាប់ នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៥ ក្រោយបទឈប់បាញ់ចូលជាធរមាន វេលាម៉ោង១២យប់ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥។ កម្ពុជាអំពាវនាវឱ្យភាគីថៃ ដោះលែងកងទ័ពកម្ពុជាទាំង ១៨រូប ដោយគ្មានលក្ខខណ្ឌ ប្រកបដោយសុខសុវត្ថិភាព ស្របតាមច្បាប់មនុស្សធម៌អន្តរជាតិ។

Ministry of Foreign Affairs and
International Cooperation
Kingdom of Cambodia
OFFICE OF THE SPOKESPERSON

---

## Updates on the situation of the Cambodia-Thailand border
## 13-15 October 2025

I. On October 14, 2025, Samdech Techo HUN Sen, President of the Senate, had a courtesy meeting and discussion with H.E. Dato Seri' Ahmad Zahid bin Hamidi, Deputy Prime Minister and Minister of Rural and Regional Development of Malaysia—

On the said occasion, Samdech Techo briefed His Excellency the Deputy Prime Minister on the situation of the border issue, including matter concerning the playing loudly sound of ghost wailing voices or other disturbing voices by the Thai side intended to annoy Cambodian citizens in Chouk Chey and Prey Chan villages, which has been happening for approximately four consecutive nights.

Samdech Techo HUN Sen emphasized that Cambodia does not wish to see any country, an ally or friend of Cambodia, condemn any country. What Cambodia desires is to encourage both sides to effectively respect the ceasefire and seek solutions to restore normalcy to the relations between Cambodia and Thailand.

He also took the opportunity to express his appreciation for the pivotal role of His Excellency the Prime Minister of Malaysia in ensuring the ceasefire and resolving the issues between Cambodia and Thailand, in his capacity as the Chairman of ASEAN.

II. **Spokesperson of the Senate of Cambodia** — In response to the statement made by the Spokesperson of the Thai Ministry of Defense on October 15, 2025, claiming that "Cambodian Senate President Samdech Techo HUN Sen had pressured Thailand to reopen the Thai-Cambodian border by October 2025" — clarified that **Samdech Techo HUN Sen, President of the Senate of Cambodia, has repeatedly reaffirmed his position.** On September 23, 2025, through his official Facebook page, **Samdech Techo HUN Sen** stated that "*since the Thai military unilaterally closed the border, Cambodia has never requested Thailand to reopen it. Cambodia merely informed the Thai side that, since Thailand was*

*the one that closed the border, it should also be the one to reopen it — there is no need for negotiation with Cambodia — and that Cambodia would reopen its side five hours later."*

III. On October 13, 2025, Samdech Maha Rathsapheathika Thipadei Khuon Sudary, President of the National Assembly of the Kingdom of Cambodia, attended the Global Leaders' Meeting on Women, in Beijing, where she delivered a statement called on the international community to closely monitor the implementation of the fragile ceasefire between Cambodia and Thailand in order to restore peace and normalcy," emphasized that, "***Peace is a necessary precondition to achieving our common goals.***"

She reiterated Cambodia's commitment to take a peaceful and restrained stance, for Cambodia does not wish to see the people of both countries suffer more from the war. She also underlined that Cambodia seeks to resolve the issue peacefully through bilateral mechanisms, adhering to the ASEAN Charter, the United Nations Charter, and international law, in order to restore normalcy to the border situation.

IV. On October 14, 2025, the Ministry of National Defence of the Kingdom of Cambodia facilitated the visit of the Interim Observer Team (IOT), led by Malaysia, along with its members, to inspect the actual locations affected by the use of a military jets to drop MK-84 bombs in Sen Rung Reurng 4 Village, Morokot Commune, Choam Ksan District, Preah Vihear Province, in order to clearly, accurately and consistently observe, verify, and report following the enforcement of the ceasefire agreement, in accordance with its mandate to ensure the full and effective implementation of the ceasefire.

V. As of October 15, 2025, it has been 78 days since 18 Cambodian soldiers were illegally captured by the Thai military on July 29, 2025, shortly after the ceasefire agreement between Cambodia and Thailand entered into force at midnight on July 28, 2025. Cambodia urgently calls on the Thai side to release them unconditionally, as soon as possible, and in accordance with international humanitarian law.